# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jan-2012, 15:43
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៥ ខែមករា ឆ្នាំ២០១២

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន

---

ដាក់ដោយ៖

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

លោកមេធាវី គង់ សំអុន

លោកមេធាវី Arthur VERCKEN

លោកមេធាវី Jacques VERGES

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Clémence WITT

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

កញ្ញា Mathilde CHIFFERT
កញ្ញា អ៊ូច ស្រីផាត

**មេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីខាងការពារក្តីទាំងអស់**

## សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ភាគី អំពីបញ្ជីឈ្មោះសាក្សីដែលនឹងត្រូវកោះហៅសម្រាប់សវនាការដំបូងៗនេះ ពាក់ព័ន្ធទៅនឹងការពិនិត្យភស្តុតាង ហើយបានបង្គាប់ឲ្យភាគីធ្វើការបង្ហាញ ក្នុងបញ្ជីដំបូងរបស់ខ្លួន នូវឯកសារទាក់ទងនឹងឈ្មោះសាក្សី និងអ្នកជំនាញ ដែលអាចនឹងត្រូវបានកោះហៅក្នុងសវនាការដំបូងៗនេះ ឲ្យបានយ៉ាងយូរបំផុតត្រឹមថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១១។[1]

២. អង្គជំនុំជម្រះសាលាដំបូង បានបន្ថែមថា រាល់ការជំទាស់ជាយថាហេតុទាក់ទិននឹងការទទួលយកឯកសារទាំងនោះ ឬប្រភេទឯកសារណាមួយ ត្រូវដាក់សេចក្តីជំទាស់នោះឲ្យបានក្នុងអំឡុងពេល ១០ ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីឯកសារ និងវត្ថុតាង ដែលភាគីមានបំណងបង្ហាញនៅសវនាការ ដំណាក់កាលដំបូងនៃការជំនុំជម្រះនេះ។ [2]

៣. អង្គជំនុំជម្រះសាលាដំបូងក៏បានសុំឲ្យភាគីបញ្ជាក់ប្រាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ ថា "តើខ្លួនជំទាស់នឹងឯកសារណាខ្លះប្រសិនបើមាន ក្នុងចំណោមឯកសារសេសសល់ ដែលខ្លួនចង់ឲ្យភាគីបដិបក្ខទទួលស្គាល់ ពាក់ព័ន្ធនឹងចំណុចអង្គហេតុទាំងបួន ដែលត្រូវជំនុំជម្រះ នៅដំណាក់កាលដំបូង ព្រមទាំងមូលដ្ឋាននៃការជំទាស់ដំបូង" ។ [3]

៤. នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ដោយហេតុថា លោក ខៀវ សំផន ព្រមទាំងក្រុមមេធាវីការពារក្តីរបស់លោក មិនអាចពិនិត្យមើលឯកសាររាប់ពាន់ ក្នុងរយៈពេលតែ១០ថ្ងៃបាន លោក ខៀវ សំផន ក៏សូមដាក់ការជំទាស់ចំពោះការមិនទទួលយកឯកសារ "តាមប្រភេទនៃឯកសារវិញ"។ [4]

---

[1] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូងៗ ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ E131/1 ("អនុស្សារណៈ" ទំព័រទី២ កថាខណ្ឌទី១។

[2] ដូចខាងលើ

[3] ដូចខាងលើ ទំព័រទី២ កថាខណ្ឌទី២

[4] សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់

៥. ថ្ងៃនេះ លោក ខៀវ សំផន នៅតែពុំអាចពិនិត្យឯកសាររាប់ពាន់ដែលនៅសេសសល់បាន។[5] ហេតុនេះ លោកសូមយោងទៅលើអំណះអំណាងទាំងឡាយដែលលោកបានលើកឡើងកាលពីពេលមុននេះ។[6]

៦. ក៏ប៉ុន្តែ លោក ខៀវ សំផន ក៏សូមបញ្ជាក់ផងដែរថា ការជំទាស់មិនទទួលឯកសារ តាមប្រភេទនៃឯកសារ មិនមែនមិនរាប់បញ្ចូលការជំទាស់ទៅនឹងឯកសារដោយឡែកណាមួយឡើយ។ ផ្ទុយទៅវិញ លោកបានវាយតម្លៃថា **ដាច់ខាត** ត្រូវធ្វើការពិនិត្យលើវត្ថុតាង**នីមួយៗ** ដែលភាគី និងអង្គជំនុំជម្រះ លើកយកមកបង្ហាញនៅក្នុងខណៈពិភាក្សាតទល់គ្នា។

៧. លោក ខៀវ សំផន សូមប្រកាសថា ចាប់ពីពេលនេះតទៅ លោក**សូមជំទាស់ "រាល់ការសន្មតទទួលយកនូវឯកសារណាមួយ"**[7] ហើយលោកនឹងជំទាស់ទៅនឹងរាល់ឯកសារទាំងឡាយណាដែលខ្លឹមសារមិនទាន់ត្រូវបានអាន សង្ខេប ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណ**យ៉ាងសមស្រប** ក្នុងសវនាការ (ស្របតាមវិធាន ៨៧.៣ នៃវិធានផ្ទៃក្នុង)[8] ឬ អាចនិយាយម្យ៉ាង

---

កាលដំបូង (ថ្ងៃទី២៨ ខែវិច្ឆិកា - ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១) ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E131/6

[5] អនុស្សរណៈ ទំព័រទី២-៣ ៖ "បន្ទាប់អង្គជំនុំជម្រះបានពិនិត្យឯកសារដែលស្នើសុំដោយភាគី យើងឃើញថា ៖ - សហព្រះរាជអាជ្ញា (...) បានបញ្ជាក់ថាឯកសារចំនួន ៤៧៦៨ (...) សុទ្ធតែពាក់ព័ន្ធទៅនឹងអង្គហេតុសម្រាប់ដំណាក់កាលទាំងបួននៃការជំនុំជម្រះ (...)។ - សហមេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឯកសារទាំងអស់ នៅក្នុងសំណុំរឿងដែលមានកត់សម្គាល់នៅត្រង់ជើងទំព័រ នៃដីកាដំណោះស្រាយ ព្រមទាំងឯកសារបន្ថែមចំនួន ២៤ទៀត ដែលបានបញ្ចូលទៅក្នុងសំណុំរឿង"។

[6] សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀតសម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង (ថ្ងៃទី២៨ ខែវិច្ឆិកា - ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១) ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E131/6

[7] ប្រតិចារឹកនៃសវនាការ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ឯកសារ E1/23.1 ទំព័រទី៦៥ បន្ទាត់ទី ២១-២៥ ចម្លើយទៅនឹងសំណួររបស់ភាគី ក្នុងសវនាការដំបូងនៃសំណុំរឿង ០០២ និងការរៀបចំប្រជុំក្រៅផ្លូវការជាមួយអ្នកច្បាប់ កាលពីថ្ងៃទី១៨ វិច្ឆិកា ២០១១ អនុស្សរណៈ ថ្ងៃទី១៧ វិច្ឆិកា ២០១១ ឯកសារ E 141 ទំព័រ 3។

[8] វិធាន៨៧.៣ នៃវិធានផ្ទៃក្នុង ដែលត្រូវបានធ្វើវិសោធនកម្ម បន្ទាប់ពីបានអនុវត្តនៅក្នុងសំណុំរឿង ០០១ នៅក្នុងសេចក្តីសម្រេចធ្វើឡើងដោយ អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងចំណុចទាំងនោះ ៖ ប្រតិចារឹកនៃសវនាការ នាថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D288/4.22.1 ទំព័រទី៤ ដល់ទី៧ ។ សាលក្រមលើការជំនុំជម្រះឌុច ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌទី៥៧ កំណត់ជើងទំព័រលេខ ៨៣

ទៀតថា ត្រូវធ្វើយ៉ាងណា ដើម្បី“*ឲ្យភាគី និងអង្គជំនុំជម្រះមានឱកាសវាយតម្លៃលើឯកសារនោះ*”។[9]

| | | | |
|---|---|---|---|
| | លោកមេធាវី គង់ សំអុន<br>លោកមេធាវី Arthur VERCKEN<br>លោកមេធាវី Jacques VERGÈS | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[9] សំណុំរឿង០០១ ប្រតិចារឹកនៃសវនាការ នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩ ឯកសារ D288/4.22.1 ទំព័រទី៦ បន្ទាត់ទី ២៣-២៤។